**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្ដាល**

សំណុំរឿងព្រហ្មទណ្ឌលេខៈ ១៦៨៤ អក
ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២២
សាលក្រមលេខៈ ៤៣ (ច)
ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៤

**តាមនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តកណ្ដាល**

-បានបើកសវនាការជំនុំជម្រះសាធារណៈ នៅសាលាដំបូងខេត្តកណ្ដាល នៅថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២៤ ដោយមានសមាសភាពដូចតទៅ:

**សមាសភាពជំនុំជម្រះ**

លោក [redacted] ចៅក្រមជំនុំជម្រះ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្ដាល

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្ដាល

**មេធាវីការពារឱ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ខុន**

លោក [redacted]

**មេធាវីការពារឱ្យជនជាប់ចោទឈ្មោះ [redacted] គុជសា**

លោក [redacted]

ដើម្បីជំនុំជម្រះ សំណុំរឿងព្រហ្មទណ្ឌលេខៈ ១៦៨៤ អក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២២ ដែលមានជនជាប់ចោទ ៖

១-ឈ្មោះ [redacted] គុជសា ភេទប្រុស អាយុ ២៦ឆ្នាំ ជនជាតិខ្មែរ មុខរបរ បើកបររថយន្តកុងទីន័រ កន្លែងកំណើត ភ[redacted] ខេត្តស្វាយរៀង និងទីលំនៅបច្ចុប្បន្ននៅភ[redacted] ខេត្តស្វាយរៀង ឪពុកឈ្មោះ [redacted] វុទ្ធី (រស់) ម្ដាយឈ្មោះ [redacted] មុំ (រស់) ប្រពន្ធឈ្មោះ [redacted] ស្រីល័ក្ខ ជានីតិជន ទោសពីមុន៖ គ្មាន (ក្រៅឃុំ)។

ត្រូវជាប់ចោទពីបទ៖ បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពកាតព្វកិច្ចបណ្ដាលឲ្យអ្នកដទៃស្លាប់ ប្រព្រឹត្តនៅភូមិផ្លូវជាតិលេខ១ ចន្លោះគីឡូម៉ែត្រលេខ២៥ ២៦ ស្ថិតនៅភូមិស្ដៅកន្លែង ឃុំដីឥដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្ដាល កាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២២ វេលាម៉ោង ២ និង៣០នាទី តាមបញ្ញត្តិផ្ដន្ទាទោសតាមមាត្រា ៨៥ នៃច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ខុន ភេទប្រុស អាយុ ៤៥ឆ្នាំ មុខរបរ ជាងសំណង់ ទីលំនៅបច្ចុប្បន្ន នៅភូមិកណ្ដាលខាងលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្ដាល ជានីតិជន។/

Scanned with CamScanner

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុខា ភេទស្រី អាយុ ៦០ឆ្នាំ មុខរបរ កសិករ ទីលំនៅបច្ចុប្បន្ននៅភូមិក្រោល ឃុំគោខ្ចក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ជានីតិជន។

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ៖ ១១២៩ ដកសព/២៣ ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល ។

បានឃើញ ដីកាដំណោះស្រាយលេខ៖ ១១៩៤ ដកដស ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាល ។

បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ៖ ០០៤ ជជ/២៤ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៤ របស់ប្រធានសាលាដំបូងខេត្តកណ្ដាល ។

## ការប្រព្រឹត្តរបស់ជនជាប់ចោទ

កាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២២ វេលាម៉ោង០២ និង៣០នាទី មានករណី "បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពកាតព្វកិច្ច បណ្ដាលឲ្យស្លាប់អ្នកដទៃ" ប្រព្រឹត្តនៅលើផ្លូវជាតិលេខ១ ចន្លោះគីឡូម៉ែត្រលេខ២៥-២៦ ស្ថិតនៅភូមិស្ដៅកន្លែង ឃុំដីឥដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្ដាល បង្កឡើង ដោយជនត្រូវចោទឈ្មោះ [redacted] កុសល ភេទប្រុស អាយុ២៧ឆ្នាំ បានបើកម៉ូតូ ០១គ្រឿងម៉ាក HONDA DREAM C125 ពណ៌ខ្មៅ ពាក់ស្លាកលេខ កណ្ដាល 1AQ-7370 រួមដំណើរដោយឈ្មោះ [redacted] សុខា ភេទប្រុស អាយុ១៧ឆ្នាំ (ជិះកណ្ដាល) និងឈ្មោះ [redacted] វិច្ឆិកា ភេទប្រុស (ជិះក្រោយ) ក្នុងទិសដៅ ពីភ្នំពេញ-អ្នកលឿង ពេលនោះក៏មានម៉ូតូចំនួន ០៣គ្រឿងមិនស្គាល់ម៉ាកមានគ្នា ប្រហែល៤ ទៅ ៥នាក់ បានជិះដេញម៉ូតូរបស់អ្នកទាំងបីតាំងពីម្ដុំវត្តដីឥដ្ឋ រហូតជិតដល់ចំណុចកើតហេតុស្រាប់តែក្រុមម៉ូតូនោះបានយកម្ជុកការពារវាយចំក្បាលរបស់ឈ្មោះ [redacted] វិច្ឆិកា បណ្ដាលឱ្យធ្លាក់ពីលើម៉ូតូ តែជនត្រូវចោទឈ្មោះ [redacted] កុសល មិនបានឈប់ម៉ូតូទេ គឺនៅបន្តដំណើរទៅមុខទៀត រីឯក្រុមម៉ូតូរបស់ឈ្មោះ [redacted] កុសល ដដែល លុះដល់ចំណុចកើតហេតុខាងលើ ស្រាប់តែជនត្រូវឈ្មោះ [redacted] កុសល ដែលកំពុងឌុបឈ្មោះ [redacted] សុខា បានបើកជ្រុលចង្កូតទៅបុកជាមួយ រថយន្ត០១គ្រឿងម៉ាក HYUNDAI ពណ៌ទឹកប្រាក់ ពាក់ស្លាកលេខ ភ្នំពេញ 3E-3774 សណ្ដោងសីម៉ីរ៉ឺម៉ក ពាក់ស្លាកលេខ ស្វាយរៀង 4A-0042 បើកបរដោយជនត្រូវចោទឈ្មោះ [redacted] គុជសា បើកបរដោយធ្វេសប្រហែស មិនយកចិត្តទុកដាក់ក្នុងទិសដៅផ្ទុយគ្នាពីអ្នកលឿង-ភ្នំពេញ បណ្ដាលឱ្យជនត្រូវចោទឈ្មោះ [redacted] កុសល និងអ្នករួមដំណើរឈ្មោះ [redacted] សុខា ស្លាប់ទាំងពីរនាក់នៅនឹងកន្លែង និងខូចខាតម៉ូតូចំនួន០១គ្រឿង។ បន្ទាប់មកសមត្ថកិច្ច ក៏បានសាងសំណុំរឿងបញ្ជូនមកកាន់អយ្យការអមសាលាដំបូងខេត្តកណ្ដាល ដើម្បីចាត់ការបន្តតាមនីតិវិធី។

## នាពេលសវនាការ

-ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ
-ក្រោយពីបានស្ដាប់ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី
-ក្រោយពីបានស្ដាប់ចម្លើយរបស់សាក្សី
-ក្រោយពីបានស្ដាប់របាយការណ៍របស់មន្ត្រីយុត្តិធម៌
-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី
-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ
-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ
-ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់។៚



Scanned with CamScanner

# សាលាដំបូងខេត្តកណ្តាល
# យល់ឃើញថា

**ក.អំពីពិរុទ្ធជនៈ**

១-តាមដីកាដំណោះស្រាយលេខៈ ១១៩៤ ដកដស ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្តាល ដែលបានសម្រេចបញ្ជូនជនជាប់ចោទឈ្មោះ [redacted] វុទ្ធី ភេទប្រុស អាយុ ២៦ឆ្នាំ មកតុលាការដើម្បីជំនុំជម្រះពីបទៈ បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពកាតព្វកិច្ចបណ្តាលឲ្យអ្នកដទៃស្លាប់ ប្រព្រឹត្តនៅភូមិផ្លូវជាតិលេខ១ ចន្លោះគីឡូម៉ែត្រលេខ២៥ ២៦ ស្ថិតនៅភូមិស្តៅកន្លែង ឃុំដីឥដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២២ វេលាម៉ោង ២ និង៣០នាទី តាមបញ្ញត្តិផ្តន្ទាទោសតាមមាត្រា ៨៥ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

២-ជនជាប់ចោទឈ្មោះ [redacted] គុជសា បានឆ្លើយសារភាពថាៈ នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២២ វេលាម៉ោងប្រហែល ៦ល្ងាច ខ្លួនបើករថយន្តកុងទីន័រ០១គ្រឿង ហើយពុំមានអ្វីនៅក្នុងទូរកុងទីន័រទេ ដោយបើកចេញពីផែស្ងួនបាវិត ខេត្តស្វាយរៀង ឆ្ពោះមករោងចក្រ សួរឡា នៅខណ្ឌកំបូល រាជធានីភ្នំពេញ ដើម្បីដឹកឥវ៉ាន់សួរឡាត្រឡប់ទៅបាវិតវិញ។ ខ្លួនបើកបរតែម្នាក់ ឯងទេ ពេលបើកមកដល់ចំណុចអ្នកលឿង ម៉ោងប្រហែល៨យប់ ខ្លួនក៏សម្រាកសិនលុះដល់ម៉ោង១ និង ៥០នាទី ឆ្លងចូលថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២២ ខ្លួនក៏បានបើករថយន្តបន្តដំណើរទៅមុខទៀត ហើយខ្លួន បើកបរក្នុងល្បឿន ៤០-៥០គីឡូម៉ែត្រក្នុង តែក្នុង ១ម៉ោង ១ម៉ោង មានបើកភ្លើងបំភ្លឺផ្លូវប្រាំងរថយន្តចាប់ស៊ុធម្មតា ហើយ ខ្លួនពុំបានហុបគ្រឿងស្រវឹងមុនពេលចេញមកទេ មានដាក់ខ្សែក្រវ៉ាត់ត្រឹមត្រូវ ស៊ុផ្លេរថយន្តលឺច្បាស់ៗកញ្ចក់មុខ និងក្រោយមើលឃើញច្បាស់ ហើយខ្លួនក៏ជាអ្នកឧស្សាហ៍បើកចេញ តែពេលមេឃងងឹត ដោយសារតែតម្រូវតាមជើងឥវ៉ាន់។ ស្រាប់តែបើកជិតមកដល់ចំណុចកើតហេតុ ក៏បានឃើញម៉ូតូចំនួន ០៤គ្រឿង មានចំងាយប្រហែល១០០ម៉ែត្រ ពីខាងមុខរថយន្តរបស់ខ្លួនក្នុងនោះម៉ូតូ០២គ្រឿងជិះប្រកាន់ស្តាំ ក្នុង១ម៉ូតូជិះគ្នា០២នាក់ និងម៉ូតូ០២គ្រឿងទៀតជិះប្រកាន់ឆ្វេង (ជិះបញ្ច្រាស់ទិស) ក្នុង១ម៉ូតូជិះគ្នា០២ នាក់ដែរ ហើយក្នុងចំណោមម៉ូតូ០២គ្រឿងដែលជិះប្រកាន់ឆ្វេង (ជិះបញ្ច្រាស់ទិស គឺមានម៉ូតូ០១គ្រឿង ជិះមិនបានបើកភ្លើងបំភ្លឺផ្លូវទេ ហើយម៉ូតូទាំង០២គ្រឿងបានបើកក្នុងល្បឿនយ៉ាងលឿនតម្រង់មកចំពីមុខរថយន្តរបស់ខ្លួនភ្លាមៗខ្លួនមានអារម្មណ៍ថាមិនស្រួលទេ ឃើញមកកាន់តែកៀករថយន្ត ពេលនោះខ្លួនបានស៊ុផ្លេជាច្រើនដង ខំញ៉ាក់ភ្លើងទៅអ្នកបើកបរម៉ូតូទាំងពីរនោះឱ្យដឹង និងបានជាន់ហ្វ្រាំង ចំនួន០២ជើង ជិតអស់ល្បឿនទៅហើយ រួចហើយបានកាច់ចង្កូតមកខាងស្តាំដៃរបស់ខ្លួន ប្រឹងងាកគេចពីម៉ូតូនោះ ហើយក៏បានគេចផុតម៉ូតូចំនួន០១គ្រឿង នៅសល់ម៉ូតូ០១គ្រឿង ទៀតដែលមិនបើកភ្លើងបំភ្លឺផ្លូវបើកមកចូលរថយន្តរបស់ខ្លួនចំខាងមុខផ្នែកខាងស្តាំនៃរថយន្តខ្លួនពេញទំហឹងតែម្តង ហើយពេលបុកភ្លាមរថយន្តរបស់ខ្លួនក៏នៅមានល្បឿនទៅមុខមិនទាន់អស់ភ្លាមទេ" ហើយម៉ូតូកៀបជាប់ពីក្រោមរថយន្តរបស់ខ្លួនអូសទៅមុខមានចំងាយប្រហែលជាង២០ម៉ែត្រទើបឈប់មួយកន្លែង។ បន្ទាប់មក ពេលខ្លួនរៀបនឹងបើកទ្វាររថយន្តចុះមកមើល ស្រាប់តែមានម៉ូតូចំនួន០២គ្រឿងក្នុងចំណោម ម៉ូតូ០៤គ្រឿង ខាងលើ បានបកត្រឡប់មកវិញ ហើយបានមកទាញទ្វាររថយន្តរបស់ខ្លួន និងនិយាយគំរាមខ្លួនថា បើចុះរត់នឹងវ៉ៃឱ្យងាប់ ភ្លាមៗខ្ញុំក៏ចាក់សោរទ្វាររថយន្តជាប់មិនទាន់ចុះទៅណានោះទេរង់ចាំប្រហែលកន្លះម៉ោងទើបឃើញសមត្ថកិច្ចមកដល់ ទើបខ្លួនហ៊ានចុះទៅជាមួយសមត្ថកិច្ច ហើយក៏បានឃើញម៉ូតូ និងមនុស្សចំនួន០២នាក់ស្លាប់ នៅពីក្រោមក្បាលរថយន្តរបស់ខ្លួនកៀបជាប់ជាមួយម៉ូតូរបស់គាត់។ បន្តមកទៀត សមត្ថកិច្ចក៏បាននាំខ្លួនទៅសាកសួរនៅប៉ុស្តិ៍នគរបាលដីឥដ្ឋ បន្ទាប់មកសមត្ថកិច្ចបាននាំខ្លួនមកកាន់អធិការដ្ឋាននគរបាលស្រុកកៀនស្វាយ ដើម្បីសាកសួរបន្ថែមទៀត ពេលសាកសួរចប់សមត្ថកិច្ចបានឃាត់រូបខ្លួននៅទីនោះអស់០១យប់ ទើបស្អែកឡើងម៉ោងប្រហែល៣រសៀល សមត្ថកិច្ចរកឃើញថា ការបើកបររបស់ខ្លួនគ្មានកំហុស

ទើបសមត្ថកិច្ចគាត់អនុញ្ញាតឱ្យខ្លួនត្រឡប់ទៅផ្ទះវិញ។ រីឯរថយន្តកុងទីន័រត្រូវបានសមត្ថកិច្ចនាំយកមករក្សាទុកនៅអធិការដ្ឋាននគរបាល ស្រុកកៀនស្វាយ។ ខ្លួនសូមទទួលស្គាល់ថាចំពោះប័ណ្ណបើកបរដែលខ្លួនមាន គឺមិនត្រឹមត្រូវតាមប្រភេទយានយន្តដែលខ្លួនបើកបរនោះទេ។

៣-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ខុន បានឆ្លើយថា៖ កាលពីថ្ងៃកើតហេតុថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២២ ម៉ោងប្រហែល ៧ព្រឹក ក្មួយរបស់ខ្លួនឈ្មោះ [redacted] ខូច ភេទប្រុស ត្រូវជាបងបង្កើតរបស់សពឈ្មោះ [redacted] សុខា បានមកប្រាប់ខ្លួនថា [redacted]សុខា បានជួបគ្រោះថ្នាក់ចរាចរណ៍ ហើយបានឱ្យខ្លួនជួយជូនទៅមើលកន្លែងកើតហេតុ។ ពេលទៅដល់កន្លែងកើតហេតុ ខ្លួនបានឃើញសព ពីរនាក់ នៅក្រោមរថយន្ត និងឃើញក្មួយខ្លួនឈ្មោះ [redacted] សុខា បានស្លាប់ហើយនៅក្រោមរថយន្តនោះ បន្ទាប់មកសមត្ថកិច្ចដែលកំពុងចុះអន្តរាគមន៍បានធ្វើការសាកសួរថា ត្រូវសាច់ញាតិសព ហើយក៏ធ្វើឯកសារប្រគល់សព ដើម្បីយកទៅធ្វើបុណ្យតាមប្រពៃណី។ លុះដល់ម៉ោងប្រហែល ២រសៀល ទើបខ្លួនមកដាក់ពាក្យបណ្ដឹងនៅអធិការនគរបាលស្រុកកៀនស្វាយ ក្នុងរឿងនេះខ្លួនសូមទាមទារសំណងជំងឺចិត្តជាប្រាក់ចំនួន $២០០០០ (ពីរម៉ឺនដុល្លារអាមេរិក)។

៤-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុខា បានឆ្លើយថា៖ ខ្លួនត្រូវជាម្ដាយបង្កើតរបស់ឈ្មោះ [redacted] កុសល ភេទប្រុស អាយុ២៧ឆ្នាំ ដែលបានស្លាប់ក្នុងករណីគ្រោះថ្នាក់ចរាចរណ៍ នៅភូមិស្ដៅកន្លែង ឃុំដីឥដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្ដាល កាលពីថ្ងៃទី១៨ ខែ តុលា ឆ្នាំ២០២២ ដោយកូនខ្លួនជាអ្នកបើកម៉ូតូឌុបមិត្តភ័ក្ក ០១ នាក់មិនស្គាល់ឈ្មោះ ម៉ូតូ ជារបស់មិត្តភ័ក្តកូនខ្លួន ហើយមិត្តភ័ក្តកូនខ្លួនដែលជិះពីក្រោយក៏បានស្លាប់នៅកន្លែងកើតហេតុដូចគ្នាដែរ ដោយបុកជាមួយរថយន្តកុងទីន័រ។ ពេលកើតហេតុ គឺខ្លួនកំពុងនៅផ្ទះឯខេត្តព្រៃវែង ហើយត្រូវបានកូនស្រូបង្កើតឈ្មោះ [redacted] ស្រីអ៊ាប រស់នៅខេត្តពោធិ៍សាត់ទូរស័ព្ទមកប្រាប់នៅ វេលាម៉ោង៣ទៀបភ្លឺ នាថ្ងៃកើតហេតុ។ បន្ទាប់មក ខ្លួនយំនិយាយមិនចេញ និងបានទូរស័ព្ទទៅកូនស្រី បង្កើតឈ្មោះ [redacted] សុខឃា រស់នៅភ្នំពេញ ដែលនៅជិតជាងគេឱ្យមកទទួលសពប្អូនយកទៅធ្វើបុណ្យ នៅខេត្តព្រៃវែង ដោយខ្លួនមិនបានទៅផ្ទាល់ទេ គឺនៅរង់ចាំផ្ទះរៀបចំកម្មវិធីបុណ្យនិងនិមន្តព្រះសង្ឃ។ ពេលធ្វើបុណ្យចប់ ខ្លួនបានឡើងមកដាក់ពាក្យបណ្ដឹង និងភ្ជាប់ជាមួយសំបុត្រមរណភាពរបស់កូននៅ អធិការដ្ឋានស្រុកកៀនស្វាយ ក្នុងរឿងនេះខ្លួនសូមទាមទារសំណងជំងឺចិត្តជាប្រាក់ចំនួន $១៨០០០ (មួយម៉ឺនប្រាំពាន់ដុល្លារអាមេរិក)។

៥-តាមកំណត់ហេតុស្ដាប់ចម្លើយរបស់សាក្សីឈ្មោះ [redacted] ផាណារ៉ា អធិការរងស្រុកកៀនស្វាយ នៅដំណាក់កាលអយ្យការ បានឆ្លើយថា៖ ពាក់ព័ន្ធនឹងករណីគ្រោះថ្នាក់ចរាចរណ៍ កើតឡើងនៅលើកំណាត់ផ្លូវជាតិលេខ១ ចន្លោះគីឡូម៉ែត្រលេខ ២៥-២៦ស្ថិតក្នុងភូមិស្ដៅកន្លែង ឃុំដីឥដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្ដាល កាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២២ វេលាម៉ោង០២ និង ៣០នាទីទៀបភ្លឺ រវាងម៉ូតូ០១គ្រឿង ម៉ាកហុងដាឌ្រីម C125 ពណ៌ខ្មៅ ពាក់ផ្លាកលេខកណ្ដាល 1AQ-7370 បើកបរដោយឈ្មោះ [redacted] កុសល ភេទប្រុស អាយុ២៧ឆ្នាំ រួមដំណើរចំនួន០១នាក់ ឈ្មោះ [redacted] សុខា ភេទប្រុស អាយុ ១៧ឆ្នាំ ក្នុងទិសដៅពីភ្នំពេញ ទៅអ្នកលឿង ជាមួយរថយន្ត០១គ្រឿងម៉ាក HYUNDAI ពណ៌ទឹកប្រាក់ ពាក់ផ្លាកលេខ ភ្នំពេញ 3E-3774 សណ្ដោងសឺមីរ៉ឺម៉កពាក់ផ្លាកលេខស្វាយរៀង 4A-0042 បើកបរដោយឈ្មោះ [redacted] គុជសា ភេទប្រុស អាយុ ២៦ឆ្នាំ ក្នុងទិសដៅផ្ទុយគ្នាពីអ្នកលឿងទៅភ្នំពេញ បណ្ដាលឱ្យស្លាប់អ្នកជិះម៉ូតូទាំង០២នាក់, ខូចខាតម៉ូតូ០១គ្រឿងធ្ងន់ និងខូចខាតរថយន្តខាងមុខផ្នែកខាងស្ដាំ។ ខ្លួនសូមបញ្ជាក់ថា នៅថ្ងៃកើតហេតុ នាយប៉ុស្តិ៍ដីឥដ្ឋបានរាយការណ៍មកខាងអធិការស្រុកកៀនស្វាយថា មានករណីគ្រោះថ្នាក់ចរាចរណ៍ស្លាប់មនុស្សចំនួន០២នាក់ រវាងម៉ូតូ និងរថយន្តពេលនោះរូបខ្លួនផ្ទាល់បានដឹកនាំកម្លាំងជំនាញចរាចរណ៍ចំនួន០២រូបទៀត ចុះទៅដល់កន្លែងកើតហេតុពេលទៅដល់លោកអធិការស្រុក ក៏បានអញ្ជើញទៅដល់ដែរ ហើយកម្លាំងជំនាញរបស់ខ្លួនក៏ចាប់ផ្ដើម ពិនិត្យកន្លែងកើតហេតុ ស្លាកស្នាម ដើម្បីរកចំណុចបុកពីដំបូង។ នៅពេលដែលខាងជំនាញរបស់ខ្លួន មើលចប់ក៏បានបាញ់ថ្នាំកំណត់ចំណុចដែលបុកដំបូង និងស្លាកស្នាមដែលមាននៅលើផ្លូវ ថែមទាំងបាន វាស់វែង



Scanned with CamScanner

កសាងសំណុំរឿងទៅតាមនីតិវិធី។ ពេលកម្លាំងជំនាញទៅដល់កន្លែងកើតហេតុភ្លាម គឺបាន ឃើញម៉ូតូបុកជាប់ជាមួយរថយន្ត ហើយអ្នកបើកបរម៉ូតូស្លាប់ផ្លានៅក្រោមក្បាលរថយន្ត និងអ្នករួម ដំណើរចំនួន០១នាក់ គឺស្លាប់ជាប់នឹងម៉ូតូជាមួយរថយន្ត រីឯអ្នកបើកបររថយន្ត គឺខាងប៉ុស្តិ៍ដីឥដ្ឋបាននាំ មកសាកសួរនៅប៉ុស្តិ៍នគរបាលតាំងពីមុនជំនាញខាងខ្លួនចុះទៅដល់ម្ល៉េះ។ ទាំងសាកសព និងរថយន្ត និង ម៉ូតូ គឺខាងជំនាញមិនទាន់លើកចេញ ឬរំកិលពីកន្លែងកើតហេតុទៅណាទេ គឺរង់ចាំគ្រួសារសពខាងភាគី ម៉ូតូមកដល់នៅចន្លោះម៉ោង ៦ ទៅម៉ោង ៧ព្រឹក ហើយខាងស្រុកក៏បានរៀបចំឡានពេទ្យដើម្បីត្រៀមដឹក សពជូនគ្រួសាររបស់គាត់រួចជាស្រេច។ លុះដល់ពេលក្រុមគ្រួសារសពមកដល់ខាងជំនាញរបស់ខ្លួន ក៏បានឱ្យគាត់ពិនិត្យសព និងឱ្យគាត់ដើរមើលកន្លែងកើតហេតុដែលសមត្ថកិច្ចបានបាញ់ថ្នាំកំណត់កន្លែង មានស្លាកស្នាម ថែមទាំងផ្ញើកាំមេរ៉ាសុវត្ថិភាពជូនសាច់ញាតិគ្រួសាររបស់គាត់ ([redacted] ខុន) តាមប្រព័ន្ធតេឡេក្រាម ទើបប្រគល់សាកសពជូនទៅពួកគាត់ដើម្បីយកទៅធ្វើបុណ្យតាមប្រពៃណី។ ដោយឡែកអ្នកបើកបររថយន្តឈ្មោះ [redacted] គុជសា ក្រោយពីបានស្តាប់ចម្លើយចប់ឃើញថាៈ ពុំមានបង្កកំហុសក្នុងករណីគ្រោះថ្នាក់ចរាចរណ៍នេះទេ ហើយលោកអធិការស្រុកក៏បានសុំគោលការណ៍ពី ឯកឧត្តមព្រះរាជអាជ្ញា ដើម្បីអនុញ្ញាតឱ្យអ្នកបើកបរថយន្តត្រឡប់ទៅវិញ ដោយមានអ្នកមកធានាត្រឹមត្រូវផងដែរ និង មានចំណាឯកភាពពីលោកស្នងការរងទទួលផែនចរាចរណ៍ ដើម្បីប្រគល់ទូកុងទីន័រ និងសឺមីរ៉ឺម៉កជូនទៅ ម្ចាស់ដើមវិញ នៅតែក្បាលរថយន្តរក្សាទុកនៅអធិការដ្ឋាននគរបាលស្រុកកៀនស្វាយមកទល់ឥឡូវ។ តាមការស្រាវជ្រាវរបស់មន្ត្រីជំនាញចរាចរណ៍ខាងខ្លួនឃើញថា៖ ចំណុចកើតហេតុ គឺកើតឡើងនៅលើ ចំណែកផ្លូវនៃរថយន្ត (ខាងស្តាំដៃនៃរថយន្ត ហើយមន្ត្រីជំនាញក៏បានស្រាវជ្រាវ តាមកាំមេរ៉ាសុវត្ថិភាព របស់ផ្ទះប្រជាពលរដ្ឋនៅក្បែរកន្លែងកើតហេតុ ឃើញថា មុនកើតហេតុមានម៉ូតូចំនួន០៣គ្រឿង ក្នុងនោះ ០១គ្រឿងជិះនៅខាងស្តាំដៃ (ស្របច្បាប់ និងម៉ូតូចំនួន០២គ្រឿងទៀត ជិះនៅខាងឆ្វេងដៃ (បញ្ច្រាស់ទិស) ហើយម៉ូតូ០២គ្រឿងដែលបើកបរបញ្ច្រាស់ទិសនេះ បើកបរត្រង់ទៅមុខក្នុងល្បឿនលឿន ប្រជេញគ្នា ក្នុងនោះមានម៉ូតូ០១គ្រឿងដែលជាម៉ូតូគ្រោះថ្នាក់ បានបើកទៅបុកជាមួយរថយន្តដែលកំពុង បើកប្រកាន់ស្តាំចំខាងមុខរថយន្តផ្នែកខាងស្តាំ។ តាមការសន្និដ្ឋានរបស់ជំនាញចរាចរណ៍ខ្លួនរកឃើញថា៖ អ្នកបើកបរម៉ូតូឈ្មោះ [redacted] កុសល បើកបរធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន បើកបរមានល្បឿន លឿនប្រជេញគ្នាមិនមើលស្ថានភាពផ្លូវខាងមុខមានឧបសគ្គ ហើយរំលោភចូលចំណែកផ្លូវរបស់រថយន្ត ដែលបើកបរមកពីទិសផ្ទុយគ្នា។

៦-តាមសេចក្តីសន្និដ្ឋានរបស់លោកមេធាវី [redacted] ជាមេធាវីការពារឲ្យដើមបណ្តឹងរដ្ឋប្បវេណី បានធ្វើសេចក្តីសន្និដ្ឋានថា ៖ ឆ្លងតាមការសួរដេញដោលនៅក្នុងពេលសវនាការ កាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២២ វេលាម៉ោង ២ និង ៣០នាទី ទៀបភ្លឺ មានករណីគ្រោះថ្នាក់ចរាចរណ៍មួយកើតឡើងនៅលើផ្លូវជាតិលេខ១ ចន្លោះគីឡូម៉ែត្រ លេខ ២៥-២៦ ស្ថិតនៅភូមិស្តៅកន្លែង ឃុំដីឥដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្តាល បង្កឡើងដោយរថយន្តសណ្តោងកុងទីន័រមួយគ្រឿង ពាកផ្លាកលេខ ភ្នំពេញ 3E-3774 ធ្វើដំណើរពីកើតទៅលិច ពេលមកដល់កន្លែងកើតហេតុបានបើកបំពានគំនូសកណ្តាល ចូលទៅផ្លូវអាទិភាពម្ខាងទៀតបណ្តាលឱ្យបុកជាមួយម៉ូតូហុងដាឌ្រីម ពាក់ផ្លាកលេខ កណ្តាល 1AQ-7370 ដែលបើកបញ្ច្រាសទិស អូសរហូត ២០០ម៉ែត្រ បណ្តាលឱ្យអ្នកបើកម៉ូតូឈ្មោះ [redacted] កុសល់ ហៅ សាន់ ភេទប្រុស អាយុ ២៨ឆ្នាំ និងអ្នករួមដំណើរឈ្មោះ [redacted] សុខា ភេទប្រុស អាយុ ១៨ឆ្នាំ ស្លាប់នៅកន្លែងកើតហេតុភ្លាមៗតែម្តង។ ក្រោយពេលកើតហេតុសមត្ថកិច្ចបានចុះទៅដល់កន្លែងកើតហេតុ និងបានឃាត់ខ្លួនជនបង្កបុករថយន្ត ទៅអធិការដ្ឋាននគរបាលស្រុកកៀនស្វាយ បន្ទាប់ពីធ្វើការសាកសួររួច សមត្ថកិច្ចបានដោះលែងជនបង្កនិងប្រគល់កន្ទុយកុងទីន័រឱ្យទៅម្ចាស់វិញថែមទៀតផង ដោយមិនមានសំណងជូនជនរងគ្រោះទាល់តែសោះ។ ម្យ៉ាងទៀតជនជាប់ចោទបើកដោយដោយប្រើប្រាស់បណ្ណ័បើកបរខុសពីប្រភេទយានយន្ត ដែលខ្លួនអាចបើកបានថែមទៀតផង។/៨



Scanned with CamScanner

៧-តាមរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌លេខ ២៨ របក ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២ របស់អធិការដ្ឋាននគរបាលស្រុកកៀនស្វាយ បានបញ្ជាក់ថា៖ កាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២២ វេលាម៉ោង២និង៣០នាទី នៅលើផ្លូវជាតិលេខ១ ក្នុងចន្លោះ គីឡូម៉ែត្រ២៥-២៦ ចំណុចភូមិស្លៀកន្លែង ឃុំដីឥដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្តាល មានករណីគ្រោះថ្នាក់ ចរាចរណ៍កើតឡើងរវាងរថយន្តម៉ាកHYUNDAI ពណ៌ទឹកប្រាក់ ប្រភេទក្បាលសណ្តោង ផ្លាកលេខភ្នំពេញ 3E-3774 សណ្តោងសឺមីរ៉ឺម៉កពាក់ផ្លាកលេខ ស្វាយរៀង4A-0042 បើកបរដោយឈ្មោះ [redacted] គុជសា ភេទ ប្រុសអាយុ២៦ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរបើកបររថយន្តមានទីលំនៅ ភូមិថ្នល់ សង្កាត់ចេក ក្រុងស្វាយរៀង ខេត្តស្វាយរៀង ដែលបើកមានទិសដៅ ពីអ្នកលឿងទៅភ្នំពេញ តាមផ្លូវជាតិលេខ១។ ពេល បើកមកដល់ចំណុចកើតហេតុខាងលើ មានម៉ូតូម៉ាក HONDA DREAM C125 ពណ៌ខ្មៅ ប្រភេទស្រី ពាក់ផ្លាកលេខ កណ្តាល 1AQ-7370 បើកបរដោយឈ្មោះសិន កុសល ភេទប្រុស អាយុ២៧ឆ្នាំជនជាតិខ្មែរមានទី លំនៅភូមិក្រោល ឃុំគោកខ្ពស់ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង មានអ្នករួមដំណើរម្នាក់ឈ្មោះ [redacted] សុខា ភេទប្រុសអាយុ១៧ឆ្នាំ មានទីលំនៅភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល ដែលបើកមានទិសដៅផ្ទុយគ្នា។ ម៉ូតូជនរងគ្រោះបើកក្នុងល្បឿនលឿនហើយក៏ជ្រុលងាកចង្កូតទៅបុករថយន្តបណ្តាលអោយអ្នកបើកម៉ូតូឈ្មោះ [redacted] កុសល ស្លាប់ និងអ្នករួមដំណើរឈ្មោះ [redacted] សុខា ស្លាប់នៅ កន្លែងកើតហេតុ។ សាកសពបានប្រគល់អោយគ្រួសារនៃសពយកទៅធ្វើបុណ្យតាមប្រពៃណី។ ម៉ូតូខូចធ្ងន់ និងរថយន្តខូចស្រាលបានយកមករក្សាទុកជាភស្តុតាង នៅអធិការដ្ឋាននគរបាលស្រុកកៀនស្វាយ។

៨-តាមរបាយការណ៍លេខ ១១០ ដជគ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២៣ របស់អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក នៃក្រសួងសាធារណការ និងដឹកជញ្ជូន បានបញ្ជាក់ថា បណ្ណបើកបររថយន្តលេខ D2.SVR00004409 របស់ជនជាប់ចោទឈ្មោះ [redacted] គុជសារ ជាប្រភេទប័ណ្ណបើកបរដឹកអ្នកដំណើរធុនធំ (ឃ២/D2) ហើយអ្នកកាន់ ប័ណ្ណបើកបរប្រភេទនេះពុំមានសិទ្ធិបើកបររថយន្តសណ្តោងសឺមីរ៉ឺម៉កឡើយ។

៩-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ ឆ្លងតាមអង្គសវនាការនេះ តំណាងអយ្យការយល់ឃើញថា៖ កាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២២ វេលាម៉ោង ០២ និង៣០នាទី ស្ថិតនៅលើផ្លូវជាតិលេខ១ ចន្លោះគីឡូម៉ែត្រ ២៥-២៦ ស្ថិតនៅភូមិស្លៀកន្លែង ឃុំដីឥដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្តាល ពិតជាមានករណី បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជាមិន ប្រុងប្រយ័ត្ន ឬមិនគោរពកាតព្វកិច្ច បណ្តាលឱ្យស្លាប់អ្នកដទៃ មួយបានកើតឡើង ដែលបង្កដោយម៉ូតូ មួយគ្រឿងម៉ាក HONDA DREAM C125 ពណ៌ខ្មៅ ពាក់ផ្លាកលេខ កណ្តាល 1AQ-7370 ដែលបើកបរដោយ ឈ្មោះ [redacted] កុសល និងអ្នករួមដំណើរឈ្មោះ [redacted] សុខា បានបើកបុកនឹងរថយន្តមួយគ្រឿងម៉ាក HYUNDAI ពណ៌ទឹកប្រាក់ ពាក់ផ្លាកលេខភ្នំពេញ 3E-3774 សណ្តោងសឺមីរ៉ឺម៉ក់ ពាក់ផ្លាកលេខ ស្វាយរៀង 4A-0042 បើកបរដោយឈ្មោះ [redacted] គុជសា បណ្តាលឱ្យអ្នកបើកបរម៉ូតូ និងអ្នករួមដំណើរ បាត់បង់ជីវិត ប្រាកដមែន។ ដូច្នេះតំណាងអយ្យការសូមតម្កល់បទចោទប្រកាន់ តាមដីកាសន្និដ្ឋានស្ថាពរលេខ៖ ១១២៩ ដកសព ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងខេត្តកណ្តាល ទុកជាបានការដដែល។

១០-តាមសេចក្តីសន្និដ្ឋានរបស់មេធាវីការពារឲ្យជនជាប់ចោទឈ្មោះ [redacted] គុជសា ៖ ឆ្លងកាត់តាមអង្គសវនាការនេះ កូនក្តីរបស់ខ្ញុំបាទបានឆ្លើយសារភាពហើយថា ពេលកូនក្តីខ្ញុំបាទបើកបរមកដល់ចំណុចកើតហេតុចន្លោះគីឡូម៉ែត្រលេខ ២៤-២៥ ក៏បានជួបជាមួយមនុស្សមួយក្រុមមានម៉ូតូ ៤គ្រឿងកំពុងតែដេញកាប់គ្នាតាមផ្លូវ ហើយពេលនោះមិនដឹងយ៉ាងមិច ស្រាប់តែម៉ូតូរបស់ជនរងគ្រោះបើកបរទៅចូលផ្លូវម្ខាងដែលជាចំណែកផ្លូវរបស់រថយន្ត ដែលបានបើកបរបញ្ច្រាស់ទិញគ្នា បណ្តាលឱ្យជនរងគ្រោះស្លាប់។ ហើយនៅពេលកើតហេតុនេះរួច កូនក្តីរបស់ខ្ញុំបាទមិនបានរត់គេចទៅណាទេ គឺនៅក្នុងរថយន្តរហូតដល់សមត្ថកិច្ចបានមកដល់ ក៏ឡើងជិះរថយន្តជាមួយសមត្ថកិច្ចមកកាន់អធិការដ្ឋាននគរបាលស្រុកកៀនស្វាយ ហើយក្រោយការសាកសួររួចហើយ សមត្ថកិច្ចបានអនុញ្ញាតឱ្យកូនក្តីរបស់ខ្ញុំ



Scanned with CamScanner

ខ្ញុំបាទត្រឡប់ទៅផ្ទះវិញ។ ហេតុដូច្នេះនៅក្នុងរឿងនេះ កូនក្តីរបស់ខ្ញុំបាទគ្មានចេតនាបើកបរឱ្យជនរងគ្រោះស្លាប់នោះទេ គឺជនរងគ្រោះបើកបរមកចូលគន្លងផ្លូវរបស់ឡានកូនក្តីខ្ញុំបាទ។ ហេតុដូច្នេះ ស្នើឱ្យលោកចៅក្រមជំនុំជម្រះឱ្យកូនក្តីរបស់ខ្ញុំបាទរួចផុតពីបទចោទប្រកាន់នេះផង។

១១-យោងតាមសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ ,ចម្លើយសារភាពរបស់ជនជាប់ចោទ, ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ,ចម្លើយសាក្សី និងរបាយការណ៍របស់មន្ត្រីនគរបាល មានភាពស៊ីសង្វាក់គ្នា អាចបញ្ជាក់បានថា កាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ ២០២២ ពិតមានជាករណី បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពកាតព្វកិច្ចបណ្តាលឲ្យស្លាប់អ្នកដទៃ ប្រព្រឹត្តនៅលើផ្លូវជាតិលេខ១ ចន្លោះគីឡូម៉ែត្រលេខ ២៥-២៦ ស្ថិតនៅភូមិស្តៅកន្លែង ឃុំដីឥដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្តាល ដែលបង្កដោយជនជាប់ចោទឈ្មោះ [redacted] គុជសា ដូចការចោទប្រកាន់របស់តំណាងអយ្យការប្រាកដមែន។

១២-អំពើរបស់ជនជាប់ចោទបានធ្វើឱ្យប៉ះពាល់ដល់ សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ របៀបរៀបរយសង្គម ដែលបានបណ្តាលឱ្យស្លាប់អ្នកដទៃ ដែលអំពើនេះច្បាប់បានចាត់ទុកជាអំពើល្មើសផ្នែកព្រហ្មទណ្ឌតាមមាត្រា **៨៥ កថាខណ្ឌទី២ ចំណុច "ក និង គ" នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។**

១៣-ជនជាប់ចោទឈ្មោះ [redacted] គុជសា ភេទប្រុស អាយុ ២៦ឆ្នាំ ជានីតិជនមានស្មារតី និងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវ ចំពោះអំពើរបស់ខ្លួនបានប្រព្រឹត្ត។

១៤-មានភស្តុតាង ដាក់បន្ទុកគ្រប់គ្រាន់បញ្ជាក់ពីពិរុទ្ធភាពលើឈ្មោះ [redacted] គុជសា ភេទប្រុស អាយុ ២៦ឆ្នាំ (ក្រៅឃុំ) ពីបទៈ **បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពកាតព្វកិច្ចបណ្តាលឲ្យអ្នកដទៃស្លាប់** ប្រព្រឹត្តនៅភូមិផ្លូវជាតិលេខ១ ចន្លោះគីឡូម៉ែត្រលេខ២៥ ២៦ ស្ថិតនៅភូមិស្តៅកន្លែង ឃុំដីឥដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២២ វេលាម៉ោង ២ និង៣០នាទី តាមបញ្ញត្តិផ្តន្ទាទោសតាមមាត្រា **៨៥ កថាខណ្ឌទី២ ចំណុច "ក និង គ" នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។**

**ខ.អំពីសំណងជម្ងឺចិត្ត៖**

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ខុន បានទាមទារសំណងសំណងជម្ងឺចិត្ត ពីជនជាប់ចោទ និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជាប្រាក់ចំនួន $២០,០០០ (ពីរម៉ឺនដុល្លាអាមេរិក) ហេតុដូច្នេះ គប្បីតុលាការលើកយក មកពិចារណា និងសម្រេចអំពីសំណងរដ្ឋប្បវេណីជូនជនដើមបណ្តឹងរដ្ឋប្បវេណី តាមព្យសនកម្មជាក់ស្តែង។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុខា បានទាមទារសំណងសំណងជម្ងឺចិត្ត ពីជនជាប់ចោទ និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជាប្រាក់ចំនួន $១៨,០០០ (មួយម៉ឺនប្រាំបីពាន់ដុល្លាអាមេរិក) ហេតុដូច្នេះ គប្បីតុលាការលើកយកមកពិចារណា និងសម្រេចអំពីសំណងរដ្ឋប្បវេណីជូនជនដើមបណ្តឹងរដ្ឋប្បវេណី តាមព្យសនកម្មជាក់ស្តែង។

**គ.អំពីវត្ថុចាប់យក៖** ម៉ូតូម៉ាក HONDA DREAM C125 ពណ៌ខ្មៅ ពាក់ផ្លាកលេខ កណ្តាល 1AQ-7370 គប្បីប្រគល់ជូនម្ចាស់ដើមវិញ។

## <u>ហេតុដូច្នេះ សាលាដំបូងខេត្តកណ្តាល វិនិច្ឆ័យសេចក្តី</u>

១-ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] គុជសា ភេទប្រុស អាយុ ២៦ឆ្នាំ (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០៣ (បីឆ្នាំ) និងពិន័យជាប្រាក់ចំនួន ១៥,០០០,០០០ (ដប់ប្រាំលាន)រៀល ដាក់ចូលថវិការដ្ឋ ពីបទៈ **បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពកាតព្វកិច្ចបណ្តាលឲ្យអ្នកដទៃស្លាប់** ប្រព្រឹត្តនៅភូមិផ្លូវជាតិលេខ១ ចន្លោះគីឡូម៉ែត្រលេខ២៥ ២៦ ស្ថិតនៅភូមិស្តៅកន្លែង ឃុំដីឥដ្ឋ ស្រុកកៀនស្វាយ៙



Scanned with CamScanner

ខេត្តកណ្តាល កាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២២ វេលាម៉ោង ២ និង៣០នាទី តាមបញ្ញត្តិមាត្រា ៨៥ កថាខណ្ឌ២ ចំណុច “ក និង គ” នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

២-បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] គុជសា និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណីឈ្មោះ [redacted] ដារ៉ា រួមគ្នាសងសំណងជម្ងឺចិត្តឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុខា និងឈ្មោះ [redacted] ខុន ក្នុងម្នាក់ៗជាប្រាក់ចំនួន $១៥,000 (មួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក រីឯការទាមទារលើសពីនេះច្រានចោល។

៣-វត្ថុចាប់យក៖ ម៉ូតូម៉ាក HONDA DREAM C125 ពណ៌ខ្មៅ ពាក់ផ្លាកលេខ កណ្តាល 1AQ-7370 ប្រគល់ឱ្យម្ចាស់ដើមវិញ។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២៤ និងប្រកាសជាសាធារណៈថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៤ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] គុជសា និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ខុន និងឈ្មោះ [redacted] សុខា។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

| | |
|---|---|
| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជំរះ** |
| ហត្ថលេខា និងត្រា | ហត្ថលេខ និងត្រា |
| [redacted] | [redacted] |

---

"បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃ...........ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

កណ្តាល,ថ្ងៃទី...២៥...ខែមីនា ឆ្នាំ២០២៤

| | |
|---|---|
| បានឃើញ | **ក្រឡាបញ្ជី** |
| **ចៅក្រម** | |
| [redacted] | [redacted] |

បានទទួលដំណឹង

ថ្ងៃ...........ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

កណ្តាល,ថ្ងៃទី...២៦...ខែមីនា ឆ្នាំ២០២៤

**តំណាងអយ្យការ**

[redacted]



Scanned with CamScanner